# ពើងគំនូរ

ពើងគំនូរ គឺជាផ្ទាំងថ្មភក់ដ៏ធំដែលមានទីតាំងស្ថិតនៅភាគខាងកើតនៃជើងភ្នំគូលែន ដែលគេស្គាល់យ៉ាងច្បាស់ស្ថិតក្នុងសម័យអង្គរ។ សព្វថ្ងៃនេះភ្នំគូលែនត្រូវបានបង្កើតឡើងជាឧទ្យានជាតិព្រះជ័យវរ្ម័ន-នរោត្តមភ្នំគូលែនក្នុងភូមិសាស្រ្តភូមិត្រពាំងទឹម ឃុំតាសៀម ស្រុកស្វាយលើ ខេត្តសៀមរាប។ ពើងគំនូរ គឺជាបណ្តុំនៃបុរាណស្ថានជាច្រើនដែលស្ថិតនៅក្បែរៗគ្នាដូចជា អ្នកតាត្រចៀកធំ អ្នកតាដេកផ្អែង ប្រាសាទស្វាយលើ និងពើងថ្មជាច្រើនជាដើម (រូបលេខ១)។ ។ តំបន់ពើងគំនូរ ជាទីតាំងស្ងាប់ស្ងាត់ ងាយស្រួលសម្រាប់ការធ្វើតបធម៌ ដ្បិតទីតាំងនេះសំបូរដោយពើងថ្មជាច្រើននៅជុំវិញ ដែលមនុស្សមកទីជិតឆ្ងាយ ជាពិសេសតាឥសីឬតាជី និងយាយជី បានមកធ្វើតបធម៌នៅទីនេះ។[១] ក្នុងសិលាចារឹកបង្ហាញថាទីតាំងនេះត្រូវបានគេប្រើជា អាស្រមឥសីក្នុងសតវត្សទី១២ ដើម្បីធ្វើតបធម៌។ មួយវិញទៀត តំបន់នេះក៏បានបន្សល់នៅភស្តុតាងសិល្បៈជាច្រើន ឆ្លាក់ជារូបទេពក្នុងព្រហ្មញ្ញាសាសនា គំនូរពណ៌ផ្សេងៗ និងផ្ទាំងសិលាចារឹកជាដើម ដែលបានឆ្លាក់នៅលើថ្មភ្នំឬពើងថ្មដូចជា៖

១. ចម្លាក់ព្រះគណេសដៃ៨ មានទទឹង១៤២សង់ទីម៉ែត្រ កំពស់១៥៦សង់ទីម៉ែត្រ មានដៃ៨ ភ្នែក៣ ដៃស្តាំកាន់រន្ទះ, ក្អុក, ផ្កាឈូក, ដំបងដៃឆ្វេងមានកាន់ផ្កាឈូក ឆ្លាក់នៅចន្លោះថ្ម។[២] ចម្លាក់នេះត្រូវបានឆ្លាក់ដោយយកចិត្តទុក្ខដាក់ និងជាស្នាដៃមានលក្ខណៈផ្ចិតផ្ចង់(រូបលេខ២)។ នៅជាប់រូបព្រះគណេសមានរូបលិង្គ៣ តម្កល់ក្នុងស៊ុំមួយ ឆ្លាក់មិនទាន់រួច(រូបលេខ៣) ចម្លាក់ទាំងនេះឆ្លាក់ទល់មុខនិងចម្លាក់ព្រះវិស្ណុផ្ទុំ។

២. ព្រះវិស្ណុផ្ទុំ មានបណ្តោយ៣ម៉ែត្រ កំពស់១៨០ម៉ែត្រនៅលើនាគ ដៃកាន់ព្រះខ័ន ព្រះនាងលក្ស្មីកាន់ផ្កាឈូក ព្រះព្រហ្មដៃ៤ (រូបលេខ៤)។[៣] មានស្នាកស្នាមដាប់សម្រាប់ការពារទឹកហូរ និងមានសំណង់ឈើតូចមួយសម្រាប់ការពាររូបចម្លាក់នេះ។ ចម្លាក់នេះ

[១] Jessup, H.I. 2008:184-192

[២] ក្រសួងបរិស្ថាន ២០១៥:៩៤

[៣] ក្រសួងបរិស្ថាន ២០១៥:៩៤

អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ

នៅទល់មុខនឹងចម្លាក់ព្រះគណេសដៃ៨។ ចម្លាក់ព្រះវិស្ណុបានឆ្លាក់នៅលើបំណែកថ្មដែលបែកចេញពីថ្មនៃព្រះគណេសតាំងពីមុនឆ្លាក់មកម្ល៉េះ មានន័យថាចម្លាក់នេះស្ថិតនៅចន្លោះថ្ម២ដុំ។

៣. គំនូរត្រីពណ៌ក្រហម នៅផ្នែកមួយទៀតនៃពើងថ្ម ដែលមានចម្លាក់ព្រះគណេសនោះ មានគំនូរត្រីពណ៌ក្រហមព្រាលៗពេលខ្លះអាចមើលមិនឃើញ(រូបលេខ៥)។ មានប្រវែង១ម៉ែត្រ តើរូបនេះមិនច្បាស់ពីអាយុកាលប៉ុន្មាននោះទេ? ទីតាំងនេះមានស្នាកស្នាមដាប់ថ្មផ្នែកខាងលើកុំឱ្យទឹកហូរចូលក្រោមពើង ជាទីតាំងដែលអាចស្នាក់នៅ និងធ្វើពិធីបាន។

៤. ចម្លាក់ព្រះទេវៈសំខាន់ៗ និងសិលាចារឹក ផ្ទាំងចម្លាក់ត្រង់នេះជាចម្លាក់ដែលសំខាន់ជាងគេដែលមានសាច់រឿងជាច្រើនឆ្លាក់ចូលគ្នា(រូបលេខ៦)។ នៅផ្នែកខាងលើនៃរូបចម្លាក់ទាំងនេះមានស្នាកស្នាមនៃសំណង់ឈើ។ ចម្លាក់នេះយើងអាចបែងចែកជា៣ក្រុម គឺរូបកណ្ដាល ចម្លាក់ខាងឆ្វេង និងខាងស្ដាំ។ រូបកណ្ដាលមានចម្លាក់ទេវៈធំ៤ រូបលេខ១ពីខាងឆ្វេង មានកាន់ដំបងដែលមានរូបត្រីសូរ ជាទេព? ទី២ព្រះឥសូរមានព្រះនេត្រ៣ ដៃហាក់មានកាយវិការរាំ ទី៣ជារូបព្រះវិស្ណុមានព្រះហស្ត៤ ទី៤ជាទេវៈ?កាន់ដំបង។ ផ្នែកនៅចន្លោះទេពទាំង៤នោះ មានទេវៈភេទស្រី៣អង្គ រូបលេខ១មានកំពស់ត្រឹមចង្កេះបំពេញដោយផ្នែកខ្លះបំពេញឡើងវិញពីស៊ីម៉ង់ដ៍ អាចជាមហេសីនៃទេព? រូបទី២ជាមហេសីព្រះឥសូរ រូបទេពស្រីទី៣ មានដៃ៤ ជាមហេសីព្រះវិស្ណុ។ នៅចន្លោះផ្នែកខាងក្រោមនៃរូបមានរូបពួកព្រាហ្មណ៍ តូចៗ ៧អង្គ រូបព្រាហ្មទី៥ ដែលនៅចន្លោះព្រះវិស្ណុ និងមហេសីមានចារឹក ពាក្យថា (ព្រះសិវសោម) ព្រះសិវសោម ជាព្រះរាជគ្រូនៃព្រះបាទឥន្ទ្រវរ្ម័នទី១[៤] នេះបើ យោងតាមរយៈសិលាចារឹកស្ដុកកក់ធំ K.235។ សងខាងនៃចម្លាក់ក្រុមនេះមានរូបគោ២នៅសងខាង។ ចម្លាក់ផ្នែកខាងឆ្វេង រឿងព្រះវិស្ណុយោនយកកំណើតជាមនុស្សតឿ។ ព្រះវិស្ណុផ្ទុំលើនាគ លើសមុទ្រទឹកដោះមានព្រះព្រហ្ម និងព្រះនាងលក្ស្មី។ ចម្លាក់ព្រះគណេសគង់លើដំរី ព្រះស្កន្ទគង់លើហង្ស និងព្រះគង់លើគោ?(រូបលេខ៧)។ នៅផ្នែកខាងស្ដាំនៃក្រុមចម្លាក់ ដែលអាចចែកជា៣ដែរ រូបទេពភេទប្រុស ដែលមានលក្ខណៈដូចជាព្រះ

---

[៤] ទស្សនាវដ្ដី វិទ្យាស្ថានភាសាជាតិនៃព្រះរាជាណាចក្រកម្ពុជា,២០០៣:១៨

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

មហាក្សត្រ រូបព្រាហ្មម្នាក់ឈរកណ្ដាល កាន់ត្រីសូរ រូបទេពស្រី ឬមហេសីព្រះមហាក្សត្រ ដែលធ្លាក់ក្នុងស៊ុំដូចហោជាង(រូបលេខ៨)។ ជាទេវៈស្រីប្រុស ឬជាព្រះមហាក្សត្រណាមួយ។ ផ្នែកខាងក្រោមនៃចម្លាក់នោះមានសិលាចារឹកមួយ K.176 ក្នុងនេះផងដែរ ហៅថាពើង កេងកង (មិនហៅពើងគំនូរនោះទេ?) ចារជាភាសាសំស្រ្កឹត មាន១៧បន្ទាត់។[៥] សិលាចារឹកនេះ ចារនៅឆ្នាំ៩៩៦ស.ក ត្រូវនឹង១០៧៤គ.ស ក្នុងរាជព្រះបាទហស៌វរ្ម័នទី៣ (១០៦៦-១០៨០គ.ស) សោយរាជ្យបន្ទាប់ពីព្រះបាទឧទយាទិត្យវរ្ម័នទី២(១០៥០-១០៦៦ គ.ស) ដែលត្រូវជាបុត្រនៃព្រះបាទសូរ្យវរ្ម័នទី១(១០១០-១០៥០គ.ស)។

៥. ចម្លាក់ កំពស់៤ម៉ែត្រ ទទឹង២,៥ម៉ែត្រ រូបធ្លាក់មិនទាន់រួច ដែលស្ថិតនៅពើងថ្ម មួយទៀតនៅខាងត្បូង(រូបលេខ៩)។

៦. អ្នកតាដេកផ្អៀង នៅភាគខាងជើងនៃពើងគំនូរប្រមាន៥០០ម៉ែត្រ មានទឹកហូរ ដែលមានចម្លាក់ព្រះវិស្ណុផ្ទុំលើនាគ ក៏មានទំនាក់ទំនងនិងពើងគំនូរផងដែរ (រូបលេខ១០)។

តាមរយៈការសិក្សាសនេះ យើងអាចយល់ឃើញថាទីតាំងនេះជាកន្លែងសំខាន់ មួយ ជាអាស្រមនៃព្រះរាជគ្រូរបស់ព្រមហាក្សត្រ។ ដែលអាចសាងក្នុងអំឡុងឆ្នាំ១០៧៤គ. ស។ តែទីតាំងនេះក៏មានទំនាក់ទំនងនិងព្រះរាជគ្រូនៃព្រះមហាក្សត្រមុនៗផងដែរ។ ដូច ជាមានសិលាចារឹកចារពីឈ្មោះព្រាហ្មសិវសោម ដែលជាព្រះរាជគ្រូរបស់ ព្រះបាទឥន្ទ្រ វរ្ម័ន ចុងស.វទី៩ តើនេះអាចជាទីតាំងចាស់នៃសិវៈស្រម ក្នុងសម័យនោះដែរទេ? ក្រោយ មកព្រាហ្មផ្សេងៗបានប្រតិបត្តិជាបន្តបន្ទាប់ និងបានកសាងចម្លាក់ ទីសក្ការៈនាស.វទី១១គ .ស។ រហូតមកដល់ពេលបច្ចុប្បន្ននេះក៏នៅតែមានប្រជាជនទៅគោរពបូជាជាបន្តបន្ទាប់។ ទីតាំងនេះស្ថិតក្នុងឧទ្យានជាតិ ព្រះជ័យវរ្ម័ន-នរោត្តម «ភ្នំគូលែន» មានសក្ដានុពល សម្រាប់វិស្ស័យទេសចរណ៍ និងធម្មជាតិ។

---

[៥] 1966, G. Coedes, Inscriptions Du Camboge Tome 8, P.104




រូបលេខ១១





រូបលេខ១២ រូបលេខ១៣

អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ



រូបលេខ២៤



រូបលេខ២៥

អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ



រូបលេខ២៦



រូបលេខ២៧

អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ



រូបលេខ២៨



រូបលេខ២៩

អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ



រូបលេខ១០

## ឯកសារយោង

ក្រសួងបរិស្ថាន,

២០១៥ បញ្ជីបុរាណស្ថានក្នុងឧទ្យានជាតិព្រះជ័យវរ្ម័ន-នរោត្ត ភ្នំគូលែន, ទំព័រ៩៤

ទស្សនាវដ្ដី វិទ្យាស្ថានភាសាជាតិនៃព្រះរាជាណាចក្រកម្ពុជា,

២០០៣ ឆ្នាំទី៤ លេខ៤ ខែកញ្ញា, ទំព័រ ១៨

G. Coedes,

1966, *Inscriptions Du Camboge Tome 8*, P.104

Jessup, H.I.

2008. *The Rock Shelter of Peuong Kumnu and Visnu Images on Phnom Kulen. In interpreting Southeat Asia's Past: Monument, Image and Text*; Bacus, E.A., Glover, I.C., Sharrock, P.D., Eds,; NUS Press: Singgapore; Volum 2, pp. 184-192.

អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ